SOUTH OAKLEIGH COLLEGE



# កម្មវិធីសិក្សាសម្រាប់សិស្សអន្តរជាតិ


ផ្នែកអប់រំអន្តរជាតិ

នាយកដ្ឋានអប់រំ និងបណ្ដុះបណ្ដាល រដ្ឋវិកតូរៀ

41 St Andrews Place ទីក្រុងមែលប៊ើនខាងកើត រដ្ឋវិកតូរៀ 3002 ប្រទេសអូស្ត្រាលី

International@education.vic.gov.au

www.study.vic.gov.au

ផ្លូវ 16 Bakers Rd, Oakleigh រដ្ឋវិកតូរៀខាងត្បូង 3167 ប្រទេសអូស្ត្រាលី

+613 9579 2322

south.oakleigh.sc@education.vic.gov.au

# មូលហេតុត្រូវជ្រើសរើសយកវិទ្យាល័យ South Oakleigh College!



- វិទ្យាល័យ South Oakleigh College អបអរនូវភាពសម្រុះ និងលើកទឹកចិត្តឱ្យសិស្សអភិវឌ្ឍន៍ស្មារតីរឹងមាំនៃទំនួលខុសត្រូវសង្គម ការមេត្តា និងការចេះស្រឡាញ់រាប់អានគ្នាទៅវិញទៅមក។
- យើងមានសិស្សដែលនិយាយភាសាផ្សេងនៅផ្ទះក្រៅពីភាសាអង់គ្លេសចំនួនជាង 50 ភាសាដែលស្មើនឹង 55% នៃក្រុមសិស្សរបស់យើង
- គុណតម្លៃរបស់យើងផ្តោតលើគោលបំណងស្នូលរបស់យើង និងបណ្តុះតាមរយៈកម្មវិធី និងសកម្មភាពនានា។ គុណតម្លៃនៃវិទ្យាល័យរបស់យើងមាន៖ ក្តីរំពឹង ការគោរព ទំនួលខុសត្រូវ ការតស៊ូ និងការងារជាក្រុមកម្រិតខ្ពស់។
- គុណតម្លៃរបស់យើងចំពោះក្តីរំពឹងខ្ពស់ លើកទឹកចិត្តសិស្សរបស់យើងឱ្យសម្រេចបាននូវលទ្ធផល VCE និងលទ្ធផលសិក្សាដ៏លេចធ្លោ
- យើងពិតជាមានមោទនភាពក្នុងការផ្តល់ជូននូវការសិក្សាភាសាអង់គ្លេសកម្រិតខ្ពស់ជា កម្មវិធីភាសាបន្ថែម (EAL)
- យើងផ្តល់នូវនូវសកម្មភាពក្រៅកម្មវិធីសិក្សាជាច្រើន រួមទាំងដំណើរកម្សាន្តដែលរួមបញ្ចូលតម្លៃនៃការអប់រំ និងវប្បធម៌
- ក្រុមការងារសុខុមាលភាពសិស្ស ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយសិស្ស គ្រួសារ និងគ្រូបង្រៀន ដើម្បីធានាឱ្យបាននូវការបំពេញតាមតម្រូវការរៀងៗខ្លួន ដើម្បីឱ្យសិស្សមានការរីកចម្រើន



# ទំនាក់ទំនងរវាងការសិក្សា និងភាពជោគជ័យ

- សិស្សនៅវិទ្យាល័យ South Oakleigh College students បានសម្រេចនូវលទ្ធផល VCE និង ATAR ដ៏លេចធ្លោរកាលពីឆ្នាំកន្លងទៅ សាលារបស់យើងបានសម្រេចនូវពិន្ទុសិក្សាជាមធ្យម 30 ដោយមាននូវពិន្ទុ ATAR ខ្ពស់បំផុត 96.95 និង 36% នៃសិស្សដែលបានជាប់ពិន្ទុ VCE ទទួលបាន ATAR ពិន្ទុ 80+
- អត្រាចូលរៀនខ្ពស់នៅឧត្តមសិក្សា – 86% នៃនិស្សិត VCE ប្រចាំឆ្នាំ2022 បានទទួលការផ្តល់ជូនជុំទីមួយ
- សាកលវិទ្យាល័យគោលដៅកំពូលទាំង 3 សម្រាប់សិស្ស VCE ឆ្នាំ2022 មានសាកលវិទ្យាល័យ Monash University, Deakin University និង RMIT
- នៅវិទ្យាល័យ South Oakleigh College យើងមានទំនាក់ទំនងជាច្រើនជាមួយសាកលវិទ្យាល័យល្បីៗដែលផ្តល់ជូនសិស្សរបស់យើងនូវកម្មវិធីបន្ថែម និងឱកាសដ៏សម្បូរបែបដើម្បីបន្តការសិក្សារបស់ពួកគេប្រកបដោយជោគជ័យ៖
  - In2Science (RMIT) – អ្នកណែនាំដែលជានិស្សិតថ្នាក់បរិញ្ញាបត្រ ស្ម័គ្រចិត្តចំណាយពេលវេលារបស់ពួកគេដើម្បីភ្ជាប់ទំនាក់ទំនងជាមួយសិស្សពូកែរបស់យើង ដើម្បីឱ្យពួកគេចូលរួម លើកទឹកចិត្ត ចែករំលែកគំនិត និងគាំទ្រពួកគេនៅពេលចូលសិក្សានៅថ្នាក់ឧត្តមសិក្សា
  - Aviation Academy (RMIT) – ផ្សារភ្ជាប់ឧស្សាហកម្មអាកាសចរណ៍ និងអវកាស វិស័យបន្ទាប់បន្សំ និងវិស័យកម្លាំងពលកម្ម ដើម្បីបង្កើតការយល់ដឹងអំពីវិថី និងកម្មវិធីនានានៅក្នុងផ្នែកអវកាស និងអាកាសចរណ៍
  - គម្រោង AI Project ជាមួយបេក្ខភាពបណ្ឌិត Alison McGregor (សាកលវិទ្យាល័យ Victoria University) – ដោយដំណើរការកម្មវិធីជំនាញជាមួយសិស្សស្រីរបស់យើងនៅក្នុងក្លិបសិក្សា STEM ដើម្បីប្រមូលទិន្នន័យ និងបណ្តុះឱ្យមានការរីកចម្រើន និងមានសមត្ថភាពក្នុងការសរសេរកូដ សន្តិសុខសាយប័រ និងរ៉ូបូទិក
  - Monash Tech School – បង្កើតនូវកម្មវិធីត្រិះរិះពិចារណា ដើម្បីផ្តល់ជូនសិស្សនូវបទពិសោធន៍ផ្ទាល់ក្នុងជីវិតជាក់ស្តែង និងការអភិវឌ្ឍន៍ជំនាញ






# ឱកាសទទួលបានកម្មវិធីសិក្សារួម

- សកម្មភាពកម្មវិធីសិក្សារួមនៅពេញមួយឆ្នាំ ផ្តល់ឱ្យសិស្សរបស់យើងនូវឱកាសដ៏សម្បូរបែបក្នុងការចូលរួមនៅក្នុងកម្មវិធីរៀបចំឡើងដោយសាលាផ្ទាល់ និងបង្ហាញទេពកោសល្យរបស់ខ្លួន
- ឱកាសក្លាយជាអ្នកដឹកនាំនៅក្នុងក្រុមប្រឹក្សាតំណាងសិស្ស (SRC) កម្មវិធីគាំទ្រសិស្ស ប្រធានថ្នាក់សកល ប្រធានដឹកនាំក្រុមសិស្ស និងជាច្រើនទៀត។ ដោយមាននូវការបណ្តុះបណ្តាល និងកម្មវិធីជំនាញ
- ក្លឹបពង្រឹងសមត្ថភាព ដំណើរការនៅក្នុងអំឡុងពេលម៉ោងសម្រាក និងម៉ោងអាហារថ្ងៃត្រង់ រួមមានដូចជា ក្លឹបកីឡាអុក ក្លិបកិច្ចការសាលា ក្លិប STEM ក្លិបប្រព័ន្ធផ្សព្វផ្សាយ និងក្លិបជាច្រើនទៀត
- ការប្រកួតប្រជែងការសិក្សា គឺផ្តល់ជូនដល់សិស្សទាំងអស់នៅពេញមួយឆ្នាំសិក្សា ដូចជាការប្រកួត ICAS ការប្រកួតភូមិសាស្ត្រ និងប្រវត្តិសាស្ត្រអូស្ត្រាលី និងការប្រកួតប្រជែងតស៊ូមតិអន្តរសាលា
- កម្មវិធីសិល្បៈសម្តែងយ៉ាងទូលំទូលាយ រួមទាំងថ្នាក់តន្ត្រី ការផលិតមហោស្រពប្រចាំឆ្នាំ ការប្រគុំតន្ត្រី វង់ភ្លេង និងការសម្តែងទោល គឺមានផ្តល់ជូនដល់សិស្សទាំងអស់របស់យើង
- កម្មវិធីអភិវឌ្ឍន៍កីឡាជាមួយគ្រូបង្វឹកអូស្ត្រាលីល្បីៗ
  - កីឡាបាល់បោះ
  - Aussie Rules
  - ក្បាច់គុន
  - កីឡាបាល់ទាត់
  - កីឡា Netball









# សហគមន៍របស់យើង

- វិទ្យាល័យ South Oakleigh College មានទីតាំងស្ថិតនៅជាយក្រុងភាគអាគ្នេយ៍ទីក្រុងមែលប៊ើន នៅក្នុងតំបន់ដែលមានសេវាដឹកជញ្ជូនសាធារណៈល្អប្រសើរ
- វិទ្យាល័យមានទីតាំងស្ថិតនៅជិតនឹងសាកលវិទ្យាល័យ Monash University សាខា Clayton។
- ដោយមានទីតាំងស្ថិតនៅជិតមជ្ឈមណ្ឌលកីឡា និងអាងហែលទឹកបណ្ណាល័យសហគមន៍ ទីលានវាយកូនហ្គោល និងភោជនីយដ្ឋានជាច្រើន ដែលមានមុខម្ហូបជាច្រើនប្រភេទចម្រុះគ្នា
- ក៏ដូចជាស្ថិតនៅប្រហែល 10 នាទីពីមជ្ឈមណ្ឌលលក់ទំនិញ Chadstone – ដែលជាមជ្ឈមណ្ឌលលក់ទំនិញធំបំផុតនៅក្នុងភាគខាងត្បូង និងស្ថិតនៅត្រឹមតែ 10 នាទីប៉ុណ្ណោះពីឆ្នេរសមុទ្រ
- ចម្ងាយតែ 16 គីឡូម៉ែត្រប៉ុណ្ណោះពី ទីក្រុងមែលប៊ើន CBD



# គន្លឹះទទួលបានជោគជ័យក្នុងនាមជាសិស្សអន្តរជាតិ

ចាប់ពីប្រធានថ្នាក់សកលឆ្នាំ2023 របស់យើង





## មានភាពតស៊ូ

សូមកុំខ្លាចរៀនអ្វី ប្រសិនបើដំបូងឡើយអ្នកមានអារម្មណ៍ថាខុសគេ។ អ្នកអាចនឹងត្រូវចំណាយរយៈពេលមួយរយៈ ដើម្បីសម្របខ្លួនទៅនឹងប្រព័ន្ធអប់រំ និងបរិយាកាសនៅបរទេស។ រក្សាភាពវិជ្ជមាន និងរៀនសូត្រពីបទពិសោធន៍របស់អ្នក។



## ការប្រកួតប្រជែង និងកម្មវិធី

សូមកុំភ័យខ្លាចក្នុងការចាកចេញពីតំបន់សុវត្ថិភាពរបស់អ្នក និងសាកល្បងចូលរួមនៅក្នុងការប្រកួតប្រជែង និងកម្មវិធីនានាទាំងនៅក្នុងសាលា និងឆ្លងសាលា។

## ជជែកជាមួយគ្រូមុខវិជ្ជារបស់អ្នក

ប្រសិនបើអ្នកជាសិស្ស EAL ដែលត្រូវការការបកប្រែនៅថ្នាក់មួយចំនួន សូមមេត្តារំឭកលោកគ្រូអ្នកគ្រូរបស់អ្នកអំពីចំណុចនេះ ជាពិសេសនៅក្នុងមុខវិជ្ជាភាសាអង់គ្លេស និងមនុស្សសាស្ត្រ។ សួរលោកគ្រូអ្នកគ្រូថា តើពួកគាត់អាចកែសម្រួលរបៀបសួរសំណួររបស់ពួកគាត់ឱ្យមានន័យចំជាងនេះដែរឬទេ ធ្វើដូច្នេះទើបងាយស្រួលក្នុងការបកប្រែ។






## ក្លិបកិច្ចការសាលា និងការបង្ហាត់បង្រៀនបន្ថែម

ទាញយកអត្ថប្រយោជន៍ពីក្លិបកិច្ចការសាលា និងកម្មវិធីបង្ហាត់បង្រៀនបន្ថែម។ កម្មវិធីទាំងនេះ គឺមានប្រយោជន៍ជាពិសេសសម្រាប់មុខវិជ្ជាអង់គ្លេស មនុស្សសាស្ត្រ និងគណិតវិទ្យា។



## ស្វែងរកជំនួយ

សាលារបស់យើង មានគ្រូដែលមកពីវប្បធម៌ចម្រុះគ្នា ដែលអាចផ្តល់ដំបូន្មានដល់អ្នកជាភាសាដែលអ្នកត្រូវការអំពីមុខវិជ្ជាខុសៗគ្នា។ ស្វែងរកលោកគ្រូអ្នកគ្រូណាដែលនិយាយភាសាដែលអ្នកត្រូវការពីប្រធានថ្នាក់សកល ឬអ្នកសម្របសម្រួលសិស្សអន្តរជាតិ

## សុខភាពផ្លូវចិត្ត និងសុខុមាលភាព

ក្រុមការងារសុខុមាលភាពរបស់សាលារបស់យើង គឺនៅចាំគាំទ្រដល់សិស្សអន្តរជាតិ នៅពេលដែលពួកគេមានអារម្មណ៍ថាមិនមានសុខុមាលភាព (ឧទាហរណ៍ គាំទ្រលើផ្ទះស្នាក់របស់ពួកគេ កិច្ចការសាលារបស់ពួកគេ និងជំនាញសង្គមរបស់ពួកគេជាដើម)។ ក្រុមការងារសុខុមាលភាព និងលោកគ្រូអ្នកគ្រូផ្សេងៗទៀត គឺនៅចាំគាំទ្រ និងអាចសម្រេចចិត្តសម្រាប់អ្នក ដូច្នេះសូមយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់អ្នក និងកុំលាក់លៀមអ្វីឡើយ ប្រសិនបើអ្នកមានអារម្មណ៍មិនល្អនៅពេលដែលអ្នកមានសុខភាពមិនល្អ។